**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០៤៥/១៥ ក.អ.ជ.ប្រក

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ មាឃ ឆ្នាំ មមី ព.ស. ២៥៥៨
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ គ.ស ២០១៥

# ប្រកាស
## ស្តីពី
## ការកែសម្រួលសមាសភាពអង្គភាពត្រួតពិនិត្យទម្ងន់ និងទំហំយានយន្ត លើផ្លូវជនបទក្រាលកៅស៊ូ និងបេតុងក្នុងខេត្តកំពង់ស្ពឺ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ១៤២/១៤ ក.អ.ជ.ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំដែលបើកបរលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងប្រកាសលេខ ១៩៥/១៤ ក.អ.ជ/ប្រ.ក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

- យោងប្រកាសលេខ ២០៥/១៤ ក.អ.ជ/ប្រ.ក ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពត្រួតពិនិត្យទម្ងន់ និងទំហំយានយន្តលើផ្លូវជនបទក្រាលកៅស៊ូ និងបេតុងក្នុងខេត្តកំពង់ស្ពឺ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**ប្រការ ១.-** តែងតាំងសមាសភាពអង្គភាពត្រួតពិនិត្យទម្ងន់ និងទំហំយានយន្តលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុងក្នុងខេត្តកំពង់ស្ពឺ ដូចខាងក្រោម÷

១. លោក **ម៉ុក ចាន់ថន** ជាប្រធាន ជំនួសលោក **មិញ ស៊ីចាយ** ដែលបានទទួលភារកិច្ចថ្មីជាប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង។

២. លោក **ស៊ីន ស៊ំុយ** ជាសមាជិក ជំនួសលោក **ទិន ជីម** ដែលបានសុំលាឈប់។

**ប្រការ ២.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ក្រសួងអភិវឌ្ឍន៍ជនបទ

ជា សុផារ៉ា

**កន្លែងទទួល**

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងមហាផ្ទៃ*
*- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*- សាលាខេត្តកំពង់ស្ពឺ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ ១*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*